សិក្សា

លាង ហាប់អាន

# ប្រវត្តិអក្សរសាស្ត្រខ្មែរ

## សម័យនគរភ្នំដល់សម័យឧដុង្គ
## ( សតវត្សទី ១ ដល់ ១៨៥៩ )

### សំរាប់កម្មវិធីថ្មី

- សិក្សាមធ្យមភូមិ
- ឧត្តមសិក្សា
- ការស្រាវជ្រាវរបស់អ្នកអក្សរសាស្ត្រ

CA29

លាង ហាប់ អាន

# សិក្សា
# ប្រវត្តិអក្សរសាស្ត្រខ្មែរ

## សម័យនគរភ្នំដល់សម័យឧដុង្គ

## សតវត្សទី ១ ដល់ ១៨៥៩

ការផ្សាយរបស់

បណ្ណាគារ គិម-អេង លេខ ១២២

វិថីខេមរភូមិន្ទ ភ្នំពេញ

(អ្នកនិពន្ធរក្សាសិទ្ធិគ្រប់យ៉ាង)

ព.ស. ២៥១១ គ.ស. ១៩៦៧

# អារម្ភបទ

សៀវភៅ **សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ** នេះជាកម្រងអត្ថបទមេរៀនផ្នែកប្រវត្តិអក្សរសាស្ត្រខ្មែរ ដែលខ្ញុំបានរៀបរៀងបង្រៀននិស្សិតអប់រំអក្សរសាស្ត្រថ្នាក់ឆ្នាំទី ២ នៃសមាគមអ្នកនិពន្ធខ្មែរ (ឆ្នាំសិក្សា ១៩៦៦–៦៧) ។ មេរៀននេះបានទាញពុម្ពចែកចំពោះនិស្សិតពីទំព័រ ១ ដល់ ៩២ រួចម្តងហើយ ។ ខ្ញុំនឹងប្រារព្ធបញ្ចប់មួយផ្នែកខាងចុងដែលបន្តពីសម័យឧដុង្គ គឺពីឆ្នាំ ១៨៥៩ រហូតដល់បច្ចុប្បន្នកាលទៀត ។ ចំពោះផ្នែកទី ១ នេះខ្ញុំបានប្រគល់ជូនសហជីវិន **«ឆេង-ហាក់-គាង»** ដើម្បីយកទៅបោះពុម្ពផ្សាយជាសៀវភៅ ដោយមានភ្ជាប់ត្តិសេសអត្ថបទសិលាចារឹកខ្លះជាគំរូ ព្រមទាំងលក្ខណៈអក្សរខ្មែរយើងទាំង ១០ ជំនាន់ តាមបែបនៃការស្រាវជ្រាវរបស់លោកអ្នកប្រាជ្ញ **«ម៉ាសំ-ឌេស្លរ៉ូ»** ។ ខ្ញុំស្ដាយដោយរកគំរូអ្នកនិពន្ធ ឬកវីខ្លះទៀត គង់ជំនាន់ឧដុង្គពុំបានដើម្បី

ផ្តិតចុះជូនជាសំគាល់ ។ នៅពេលបោះពុម្ពលើកទី ២ ខ្ញុំនឹងលៃលកខិតខំរករូបថតអស់លោកអ្នកនិពន្ធទាំងឡាយនេះ មកចុះបំពេញបំណងអស់លោកអ្នកអានសិក្សាទុកជាកស្តុតាងខ្លះៗ

ខ្ញុំសង្ឃឹមថា សៀវភៅដែលខ្ញុំសន្មតត្រឹមតែ "ការសាកល្បង" នេះនឹងមានប្រយោជន៍ច្រើនចំពោះការស្រាវជ្រាវសិក្សាអំពីលក្ខណៈនិងបលនាអក្សរសាស្ត្រយើង ក្នុងកាលៈទេសៈដែលខ្វះខាតនូវក្បួនខ្នាតបែបនេះនៅឡើយ ។ រួមជាមួយនឹងការសិក្សាស្រាវជ្រាវផ្សាយរួចហើយ នូវសៀវភៅប្រវត្តិអក្សរសាស្ត្របែបនេះរបស់អស់លោកជាច្រើនច្បង សៀវភៅ **«សិក្សាប្រវត្តិអក្សរសាស្ត្រ»** ខ្មែររបស់ខ្ញុំនេះ មុខជានឹងបានជាឧបករណ៍បន្ថែមមួយទៀត របស់អស់លោកអ្នកដែលស្នេហាអក្សរសាស្ត្រជាតិ ដ្បិតតាមព្រះមាគ៌ាលើកស្ទួយឧបត្ថម្ភ វប្បធម៌ការិយធម៌ជាតិរបស់ **សម្តេចព្រះប្រមុខរដ្ឋ ព្រះបិតាជាតិ** ជាទីស្នេហាស្មើដោយជីវិត

របស់យើងគ្រប់ៗគ្នាជាពុំខាន ។

សូមអក្សរសាស្ត្រខ្មែរបានគង់វង្ស លូតលាស់ចំរើនជានិរន្តរ៍ ។

ភ្នំពេញ, ថ្ងៃទី ២០ សីហា ២៥១១/១៩៦៧

**លាង ហាប់ អាន**

*សាស្ត្រាចារ្យខាងភាសាខ្មែរ*

"ប្រើគេឲ្យមានប្រណី    ដេរស្តីឲ្យមានមេត្តា
ចាប់ធ្វើការឲ្យខំប្រឹង    បើខឹងឲ្យខំអត់" ។
"ចង់ឈ្នះឲ្យចាញ់
ចង់ឆ្ងាញ់ឲ្យស្ងប់
ចង់ប្រសប់ឲ្យល្ងង់"
"ចង់ចេះឲ្យមើលក្បួន    ចង់មាំមួនឲ្យខំប្រឹង
បើបន្តឹងភិនឹងជាប់    ចង់បានសំរេចឲ្យចិត្តទំ" ។

ល. ហ. អ.

# អក្សរសាស្ត្រខ្មែរពីសម័យ
# បុរាណមកសម័យបច្ចុប្បន្ន (១)

## ១– ផ្ដើមសេចក្ដី

*មុននឹងលើកយកនូវមេរៀនមកសិក្សារៀបរាប់ គប្បីដឹងជាមុនសិននូវកម្មវិធីសំរាប់ឆ្នាំសិក្សាទី ២ ស្ដីអំពីអក្សរសាស្ត្រខ្មែរសម័យបច្ចុប្បន្ន ដែលចែកជាផ្នែកលំដាប់លំដោយគ្នាដូច*

---

(១) សៀវភៅនិងអត្ថបទសំរាប់សិក្សាជាជំនួយមានដូចតទៅ :

— មើលឡើងវិញនូវមេរៀនទី ១០-១១-១២ របស់ ល.ហ.អ. ឈ្មោះ "ប្រភេទអត្ថបទ" ទំព័រ ៤៨ ដល់ ៨៦ ឆ្នាំសិក្សា វ.អ.ស. ឆ្នាំ ១៩៦៥-៦៦ សំរាប់ឆ្នាំទី១ ។

— អត្ថបទសន្និសីទរបស់ សហ. ទ្រឹញ-ហ៊ីញ ប្រធានសមាគមអ្នកនិពន្ធខ្មែរឈ្មោះ "អំពីសមាគមអ្នកនិពន្ធខ្មែរ" ១៥-១១-៦៥ ។

— សៀវភៅ "អក្សរសាស្ត្រខ្មែរ" របស់ លី-ធាមតេង បោះពុម្ពលើកទី ២ ឆ្នាំ១៩៦០ ចាប់ពីទំព័រ ៩២ តទៅ ។

— ទស្សនាវដ្ដី "កម្ពុជសុរិយា" ពិសេសពីឆ្នាំ ១៩៦៥-៦៦ ត្រង់អត្ថបទ "ឯកសារសាស្ត្រាស្លឹករឹត និងក្រាំងរបស់លោក ញ៉ុក ថែម និង "ឯកសារកម្ពុជសុរិយា" ប្រមូលរៀបរៀងដោយ សហ. ឱក-ធាម ។

គោល (១) =

— ការរៀនសារឡើងវិញ ដោយសង្ខេបអំពីប្រវត្តិអក្សរ-សាស្ត្រខ្មែរ - លក្ខណៈនៃអក្សរសាស្ត្រសម័យដើម ។

—ពីអក្សរសាស្ត្រដើមមកអក្សរសាស្ត្រសម័យ-លក្ខណៈនៃអក្សរសាស្ត្រដើមដែលនៅសព្វថ្ងៃនិងការផ្លាស់ប្ដូរផ្សេងៗ ។

— ដំណាក់ទាំង ២ នៃអក្សរសាស្ត្រសម័យបច្ចុប្បន្នៈ ពេលអាណាព្យាបាលនិងក្រោយឯករាជ្យ - ការកត់បំណាំអំពីការជ្រើសរើសវិជ្ជានិពន្ធ ។

---

— ទស្សនាវដ្ដី ឈ្មោះ «វិជ្ជាឋាន គរុកោសល្យ» លេខ ១ និង ២ ឆ្នាំ ១៩៥៨ ខែវិច្ឆិកា និងខែឧសភា ១៩៥៩ ត្រង់អត្ថបទពាក្យអ្នកនិពន្ធខ្មែររបស់លោក ញ៉ុក-ថែម ។

—អត្ថបទរបស់លោក កេង-វ៉ាន់សាក់ ផ្សាយពីមហាវិទ្យាល័យអក្សរសាស្ត្រ ឈ្មោះ «ទិដ្ឋភាពខ្លះនៃអក្សរសិល្ប៍ខ្មែរ» តែងជាភាសាបារាំង ។

— ទស្សនាវដ្ដី «អក្សរសាស្ត្រខ្មែរ» លេខ ១៩ ឆ្នាំ ទី៣ ខែវិច្ឆិកា ១៩៦៤ ពិសេសអត្ថបទ សហ. អ៊ុង-ម៉ុង និង ម៉ា ឡាយទេម ។

(១) គឺជាកម្មវិធីបង្រៀនអក្សរសាស្ត្រខ្មែរ នៅវិជ្ជាឋានអប់រំអក្សរសាស្ត្រ ឆ្នាំ ១៩៦៥-៦៦ និង ១៩៦៦-៦៧ របស់សមាគមអ្នកនិពន្ធខ្មែរ ។

– អ្នកនិពន្ធសម័យថ្មី (អ្នកនិពន្ធប្រលោមលោក កវី និងអ្នកនិពន្ធរឿងល្ខោន) និងគោលគំនិតថ្មីៗ - ការសិក្សាអំពីតួរឿង វិជ្ជានិពន្ធ រស្សុបាយ - ការសិក្សាអំពីទំនើតគួបទ :

របៀបតែងនិងបែបសរសេរ ដោយមានរៀបរាប់ឈ្មោះអ្នកនិពន្ធផង - ការសិក្សាប្រៀបធៀបនឹងសម័យមុនៗ ឬនឹងអក្សរសាស្ត្របរទេស - សម័យបច្ចុប្បន្នដទៃទៀត ។

– ការរិះគន់ជាទូទៅលើអក្សរសាស្ត្រសម័យបច្ចុប្បន្ន (រឿងប្រលោមលោក កំណាព្យ រឿងល្ខោន) ។ ទសថដែលត្រូវស្នើដើម្បីកែទូវគោលគំនិត ព្រមទាំងរបៀបតែងរឿង ។ សារសំខាន់នៃការរិះគន់ខាងអក្សរសាស្ត្រ ។

– បញ្ហានានាដែលកើតចំពោះអ្នកនិពន្ធសម័យថ្មី : ការបេះដូងទូទៅ ការផ្ទុះគំនិត ការជ្រើសរើសវិជ្ជានិពន្ធ ការលំបាកខាងផ្លូវសម្ភារៈ (បោះពុម្ពផ្សាយសៀវភៅ ។ល។) មធ្យោបាយនានា សំរាប់ដោះស្រាយបញ្ហាទាំងនោះ ។

– កត្តានៃការចំរើនរបស់អក្សរសាស្ត្រ : សមាគមអ្នក

និពន្ធខ្មែរ និងសកម្មភាពរបស់សមាគមនេះ មានការប្រជុំអក្សរសាស្ត្រ ការផ្សាយតាមវិទ្យុ សន្និសិទសាធារណៈ ប្រឡងអក្សរសាស្ត្រ ។ល។

– សកម្មភាពនៃរដ្ឋាភិបាលក្នុងវិស័យអក្សរសាស្ត្រ។

– មធ្យោបាយដើម្បីផ្សាយអក្សរសាស្ត្រ : ការសំរួលជារឿងភាពយន្ត រឿងល្ខោន និងរឿងផ្សាយតាមវិទ្យុ ។

– នៅគ្រាទស្សន៍ទៅអនាគត : តើត្រូវណែនាំអ្នកនិពន្ធក្នុងការបង្កើតអក្សរសាស្ត្រ (១) ឬទេ តាមមធ្យោបាយណា (រង្វាន់អក្សរសាស្ត្រ សិក្ខាសន្និបាតអក្សរសាស្ត្រ វិជ្ជាអប់រំខាងអក្សរសាស្ត្រ ។ល។)

## ២– ឃ្លាភ្ជាប់សេចក្តី

មុននឹងចូលទៅក្នុងការសិក្សាអំពីអក្សរសិល្ប៍ប្រវត្តិ ទៅតាមកាលសម័យនីមួយៗ យើងលើកយកកាលប្រវត្តិក្នុងប្រវត្តិ

---

(១) ការដាក់ជាអក្សរសាស្ត្រនេះ គឺដោយសរសេរតាមកម្មវិធីរបស់វិជ្ជាឋានទេ ។ តាមន័យត្រឹមត្រូវនៃពាក្យ = littérature (œuvre littéraire) ក្នុងទីនេះ គួរប្រើសព្ទថា «អក្សរសិល្ប៍» វិញ ។

វិជ្ជាខ្មែរយើងមកលាតត្រដាងជាពន្លឺនៃការសិក្សាសិន ។

## ៣– កាលប្រវត្តិតាមប្រវត្តិវិជ្ជា

តាមប្រវត្តិវិជ្ជា គេចែកសម័យកាលធំជា ៤ ផ្នែក (១) គឺ:

### សម័យកាលទី ១

សម័យនគរភ្នំ (Période du «Royaume de la montagne» គ្រិស្តសតវត្សទី ១ ដល់ទី ៦

### សម័យកាលទី ២

សម័យមុនអង្គរ (Période pré-angkorienne) :

ចាប់ពីគ.ស. ៥៥០ ដល់ ៨០២

ព្រះមហាក្សត្រសំខាន់ៗ ខ្លះក្នុងសម័យកាលនោះមាន:

– ព្រះបាទភវវរ្ម័នទី ១ (គ.ស. ៥៥០-៦០០) = Bhava-Varman 1er

---

(១) យកតាមលំនាំប្រវត្តិវិជ្ជា របស់ សហ ឌួង-សារិន មេរៀនសំរាប់មហាវិទ្យាល័យអក្សរសាស្ត្រ និងសៀវភៅប្រវត្តិវិជ្ជា ឈ្មោះ Histoire du Cambodge របស់ Mlle M. Giteau, របស់ A. Leclère, A. Dauphin Meunier, អត្ថបទនានាជាស្នាព្រះហស្តសម្តេចព្រះន.សីហនុ។